*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៤*

# II. ការងារបណ្ដាក្រសួង

## ១. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

### ប្រកាសលេខ ២២៧ ប្រក.សហវ

### ស្ដីពី

ការអនុញ្ញាតអោយបើកខុទ្ទកាល័យសវនការគណនេយ្យ (CABINET DE COMMISSARIAT AUX COMPTES ឬ AUDITING FIRM ) ឯកជន ដើម្បីបញ្ជាក់អះអាងលើគណនីរបស់សហគ្រាស

រដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណាសម្ដេចព្រះនរោត្តមសីហនុ វរ្ម័ន ស្ដីពីការតែងតាំង ព្រះរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩២ ស្ដីពីកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលបានប្រកាសប្រើដោយ ក្រឹត្យលេខ ៩០ ក្រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩២

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៩៣ ស្ដីពីកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ

-បានឃើញសារាចរលេខ: ៦៣៥ សហវ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៤ ស្ដីពីការបញ្ជាក់ថាត្រឹមត្រូវលើគណនី ( Compte certifie ) នៃសហគ្រាស

-បានឃើញប្រកាសលេខៈ ១៤៧ ប្រក.សហវ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីអត្តសញ្ញាណកម្មនៃសហគ្រាសជាប់ពន្ធលើប្រាក់ចំណេញនិង អាករលើផលរបរតាមរបបពិតប្រាកដ

- បានឃើញការចាំបាច់របស់ក្រសួង

**សំរេច**

ប្រការ ១ : គ្រប់បញ្ជីគណនេយ្យ និង រាល់លិខិតប្រកាសនៃផលរបរបស់សហគ្រាស ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការកំណត់ពន្ធតាម << របបពិតប្រាកដ >> ត្រូវមានការបញ្ជាក់ថា ត្រឹមត្រូវលើគណនី (Compte certifie ) ពីខុទ្ទកាល័យស្ទង់ការគណនេយ្យឯកជន ដែលមានការយល់ព្រមទទួលស្គាល់ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ២ បញ្ជីរាយនាមខុទ្ទកាល័យស្ទង់ការគណនេយ្យឯកជន មានចេញផ្សាយជាសាធារណៈ ព្រមទាំងមានតំកល់ទុកនៅនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៣ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទទួលស្គាល់ខុទ្ទកាល័យស្ទង់ការគណនេយ្យឯកជនទាំងនោះបានដោយផ្អែកលើលក្ខខ័ណ្ឌ ដូចខាងក្រោមនេះ ៖

អ្នកសុំបង្កើតខុទ្ទកាល័យស្ទង់ការគណនេយ្យឯកជនៈ

ក-ត្រូវមានសញ្ញាប័ត្រថ្នាក់កោសល្យវិច័យគណនេយ្យ(Expertcomptable) ឬជាស្ទង់ការគណនេយ្យ(Commissaire aux comptes )ឬសញ្ញាប័ត្រមានតំលៃស្មើ ទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ

ខ-ត្រូវមានសញ្ជាតិខ្មែរ

គ-មិនត្រូវមានការផ្តន្ទាទោសពី :

-ទោសឧក្រិដ្ឋ «ភាពជាប់ឃុំពីបទឧក្រិដ្ឋ-ភាពជាប់គុកពីបទឧក្រិដ្ឋ»

-ការប្រាសចាកសិទ្ធិពលរដ្ឋដោយសារទោសធ្ងន់បំផុត

-ទោសនៃបទមជ្ឈឹមដែលអាចនាំអោយមានការប្រាសចាកច្បាប់ រដ្ឋប្បវេណីមួយចំនួន ។

-បទឧក្រិដ្ឋឬបទមជ្ឈិមក្នុងប្រទេសដែលធ្វើអោយសៅហ្មង ដល់កិត្តិយសជាអាទិ៍ ទោសទាំងឡាយដែលនាំអោយមានការហាមប្រាម មិនអោយគ្រប់គ្រងក្រុមហ៊ុនដូចជា :

* បទឧក្រិដ្ឋខាងនីតិបញ្ញត្តិ

* បទលួច-ការក្បត់សេចក្តីទុកចិត្ត-ការឆបោក-និន្នរភាព «ទោសអ្នករលំជំនួញ-ការកំហែងមូលនិធិ-ការបញ្ចេញប្រើមូលប្បទានប័ត្រដោយគ្មានប្រាក់ក្នុងគណនីធនាគារ (Chèque sans provision) » ការប៉ះពាល់ខូចខាតដល់ ឥណទានរបស់រដ្ឋ-ការលាក់របស់ដែលបានមកពីបទល្មើស-ការប៉ុនប៉ងឬ ឃុបឃិតក្នុងបទល្មើស ទាំងនោះ ។

ឃ-ត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ចាប់តាំងពីថ្ងៃបង្កើតខុទ្ទកាល័យ ស្នង-ការគណនេយ្យរបស់ខ្លួន

ង-ត្រូវបង្ហាញនូវការធានាអះអាង ខាងសីលធម៌ថាត់ថា ជាការចាំបាច់ចំពោះ នាយកដ្ឋានពន្ធដារ ទទួលបន្ទុកកិច្ចការចុះឈ្មោះនេះ ។

ដើម្បីបំភ្លឺសេចក្តីសំរេចរបស់ខ្លួន នាយកដ្ឋាន នេះអាចធ្វើការសាកសួរ ទៅអ្នកណាម្នាក់ក៏បាន ដែលអាចបញ្ជាក់ពីកិរិយាមាយាទ ឬ ការប្រព្រឹត្តរបស់បេក្ខជន ។

ប្រការ ៤ : បេក្ខជនសុំបង្កើតខុទ្ទកាល័យស្នងការគណនេយ្យទាំងអស់ត្រូវជា អ្នកមានជីវៈសេរី និង ត្រូវស្ថិតនៅក្រៅសហគ្រាស ដែលខ្លួនត្រួតពិនិត្យបញ្ជីគណ-នេយ្យជាដាច់ខាត ។

ប្រការ ៥ : បេក្ខជនសុំបង្កើត ខុទ្ទកាល័យស្នងការគណនេយ្យ ទាំងអស់ត្រូវបញ្ជាក់បង្ហាញនៅក្នុងពាក្យសុំនូវភ័ស្តុតាងថាមានការិយាល័យ និង សំភារៈធ្វើការត្រឹមត្រូវសមរម្យដែលជាអាទិ៍មានការិយាល័យមួយសំរាប់ទទួលអតិថិជន

ប្រការ ៦ : អ្នកសុំបង្កើត ខុទ្ទកាល័យស្នងការគណនេយ្យនៅប្រទេសកម្ពុជា ក្នុងឋានៈខ្លួនជាអ្នកតំណាង នៃខុទ្ទកាល័យស្នងការគណនេយ្យ មួយដែលមានទី

តាំងនៅបរទេសត្រូវមានលក្ខណៈជាអ្នកតំណាងត្រឹមត្រូវហើយខុទ្ទកាល័យដែលខ្លួនជាអ្នកតំណាងនោះ ត្រូវមានឈ្មោះ ដែលគេទទួលស្គាល់នៅបរទេស។

ប្រការ ៧ : ការសុំចុះឈ្មោះក្នុងបញ្ជីរាយនាមខុទ្ទកាល័យស្ទង់ការគណនេយ្យឯកជន ត្រូវផ្ញើមកនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានភ្ជាប់គ្រប់ឯកសារ ដែលមានរៀបរាប់នៅក្នុងប្រការ៣ និង ប្រការ ៦ ខាងលើនេះ ។

ប្រការ ៨ : ការលុបឈ្មោះចេញពីបញ្ជីត្រូវមានសេចក្តីសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អ្នកតំណាងដោយមានបុព្វហេតុ ដូចខាងក្រោមនេះ

-ការសុំឈប់របស់សាម៉ីខ្លួន

-មានកំហុសធ្ងន់ធ្ងរខាងវិជ្ជាជីវៈ

-ការដាក់ទោសពីតុលាការ

-ការហាមឃាត់បណ្តោះអាសន្ន ឬ ជាស្ថាពរនូវការប្រកបមុខរបរមួយចំនួន។ ការលុបឈ្មោះចេញពីបញ្ជីនេះអាចជាបណ្តោះអាសន្ន ឬ ជាស្ថាពរ ។

ប្រការ ៩ : មន្ទីរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនាយកដ្ឋានពន្ធដារ នាយកដ្ឋានរបបគណនេយ្យ នាយកដ្ឋានពាក់ព័ន្ធព្រមទាំងសហគ្រាសរដ្ឋ សហគ្រាសចំរុះរដ្ឋ និង សហគ្រាសឯកជនទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ១០ : រាល់សេចក្តីសំរេចទាំងឡាយដែលផ្ទុយ នឹង ប្រកាសនេះត្រូវទុកជានិរាករណ៍។

ទេសរដ្ឋមន្ត្រី

និងជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា

សម រង្ស៊ី

* * *